**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៨៣/០០៦/២០០៤

ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤

**សេចក្តីសំរេច**

លេខ : ០៦១ /០០៣/២០០៤ កបធ.ច

ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិត ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន ១៦ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ

-បានឃើញឯកសារទទួលពីរដ្ឋសភាទាក់ទងនឹងការពិភាក្សារបស់សភាធម្មនុញ្ញ លើមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រ ១៦ រូប គឺលើសពីមួយភាគដប់នៃចំនួនតំណាងរាស្ត្រនៅរដ្ឋសភា បានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ១៤ :២៣ នាទី។ ចំនួន ១៦ រូប នេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ផងដែរ ។

-យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដោយដាក់ជាបញ្ហា ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ " *ក្រោយពីមានព្រះរាជសាររបស់ព្រះមហាក្សត្រ ស្តីពីព្រះរាជហឫទ័យចង់ដាក់រាជសម្បត្តិជាញឹកញាប់នោះមក មានការបកស្រាយខុសៗ គ្នា រវាងនាយករដ្ឋមន្ត្រី និង ក្រុមអ្នកច្បាប់មួយចំនួនស្តីពីការដាក់រាជសម្បត្តិនេះ ។* " ពាក់ព័ន្ធសំខាន់លើវាក្យខ័ណ្ឌទី ២ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត* " ។ ត្រង់នេះ មានន័យថា ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត។ ព្រះរាជតួនាទី ក្នុងការគ្រងរាជសម្បត្តិ ជាប់ជាមួយព្រះរាជតួនាទី ជាព្រះប្រមុខរដ្ឋ ដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ ។ ដូច្នេះ ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និង ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត គឺរជ្ជកាលរបស់ព្រះមហាក្សត្រត្រូវបានកំណត់ចាប់ពីពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ រហូតដល់ពេលព្រះអង្គចូលទិវង្គត ។

-យល់ឃើញថា សភាធម្មនុញ្ញបានអនុម័តមាត្រា ១២ មាត្រា ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានការជ្រើសតាំងព្រះមហាក្សត្រថ្មី ក្នុងករណីព្រះមហាក្សត្រ សោយទិវង្គតតែប៉ុណ្ណោះ ។

-យល់ឃើញថា ការដាក់រាជសម្បត្តិ មិនមានចែងក្នុងរដ្ឋធម្មនុញ្ញទេ ។

**សំរេច**

**មាត្រា ១.~** មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

**មាត្រា ២.~** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**